សមាគមសាលាត្រាជូ
SALA TRAJU ASSOCIATION

ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ

# អំពើទារុណកម្ម៖ ការណីចាំបាច់ ក្នុងការបង្ការ ជាជាងព្យាបាល

ដោយ បណ្ឌិត មាស បូរ៉ា

## មាតិកា


១. សេចក្តីផ្តើម ....... 2
២. ក្របខណ្ឌច្បាប់ ហាមឃាត់អំពើទារុណកម្ម ....... 2
២.១. និយមន័យ ....... 5
២.២. អំពើទារុណកម្ម និងអំពើប្រព្រឹត្តដទៃទៀត ....... 7
២.៣. កាតព្វកិច្ចពាក់ព័ន្ធជាមួយការហាមឃាត់អំពើទារុណកម្ម ....... 8
២.៣.១. កាតព្វកិច្ចបង្ការ ....... 9
២.៣.២. កាតព្វកិច្ចក្រោយអំពើទារុណកម្មបានកើតមានឡើង ....... 9
២.៤. ចរិតនៃការហាមឃាត់ ....... 11
២.៥. អំពើទារុណកម្មក្រោមច្បាប់កម្ពុជា ....... 13
២.៦. យន្តការទប់ស្កាត់ និង បង្កាអំពើទារុណកម្ម ....... 14
២.៧.. បញ្ហាមួយចំនួន ....... 14
២.៧.១. និយមន័យទារុណកម្ម ....... 14
២.៧.២. ចម្លើយសារភាព ....... 15
២.៨. សន្និដ្ឋាន ....... 16


©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

## ១. សេចក្តីផ្តើម

សិទ្ធិរួចផុតពីអំពើទារុណកម្ម គឺជាសិទ្ធិចំបងមួយ ក៏ប៉ុន្តែ ខ្លឹមសារលម្អិត ឬសំណួរជាច្រើនពាក់ព័ន្ធជាមួយសិទ្ធិប្រភេទនេះមិនត្រូវបានដឹងឮជាទូទៅទេ។ ជាក់ស្តែងមានសំណួរជាច្រើន ត្រូវបានលើកឡើង ទី១. តើអ្វីទៅជាអំពើទារុណកម្ម? តើអំពើទារុណកម្មខុសគ្នានឹងអំពើអមនុស្សធម៌ដែរឬទេ? តើហេតុអ្វីការហាមឃាត់អំពើទារុណកម្មត្រូវតែដាច់ខាត ទោះបីជាក្នុងអំឡុងពេលគ្រោះអាសន្នសាធារណៈ ដូចជាសង្គ្រាម?

អត្ថបទខ្លីនេះ មានគោលបំណងឆ្លើយសំណួរទាំងនេះ ហើយអះអាងថា ការបង្ការអំពើទារុណកម្ម គឺពិតជាប្រសើរជាងការព្យាបាល ដែលអាជ្ញាធរត្រូវចំណាយពេលវេលា និងធនធាន ក្នុងការនាំខ្លួនជនទទួលខុសត្រូវចំពោះអំពើទារុណកម្ម និងសងសំណងដល់ជនរងគ្រោះនៃអំពើទារុណកម្ម។

អត្ថបទជាដំបូងនឹងបរិយាយអំពីប្រវត្តិនៃការហាមឃាត់អំពើទារុណកម្ម ឯកសារអន្តរជាតិដែលចែងពីការហាមឃាត់ មុននឹងរៀបរាប់អំពីចរិតលក្ខណៈការហាមឃាត់ ហើយចុងបញ្ចប់នឹងមានការរៀបរាប់អំពីកាតព្វកិច្ចរបស់អាជ្ញាធរក្នុងការបង្ការ និងបង្ក្រាបអំពើទារុណកម្ម។

## ២. ក្របខណ្ឌច្បាប់ ហាមឃាត់អំពើទារុណកម្ម

អំពើទារុណកម្ម និងការហាមឃាត់ មានប្រវត្តិជាយូរយារណាស់មកហើយ។[1] ទារុណកម្ម ត្រូវបានប្រើជាទណ្ឌកម្ម ចំពោះអំពើល្មើសណាមួយ។ ឧទាហរណ៍ ដូចជា ការដុតមនុស្ស រហូតដល់ស្លាប់ គឺជាទារុណកម្ម ក្នុងទម្រង់ជាទណ្ឌកម្ម។[2] ក្នុងរឿងទុំទាវ ស្តេចបញ្ជាឲ្យអូសរនាស់លើក្បាលមន្ត្រីដែលបំបែកនាងទាវពីទុំដែលជាប្តីជាឧទាហរណ៍មួយនៃទណ្ឌកម្មមួយ។ ក្រោយមក ទារុណកម្មត្រូវបានគេប្រើសម្រាប់បង្ខំយកចម្លើយសារភាពពីជនសង្ស័យ ដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើស។[3] ទារុណកម្មជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពក្នុងការយកចម្លើយសារភាព ជាពិសេស ក្នុងករណីដែលបច្ចេកទេសសម្ភារៈក្នុងការស៊ើបអង្កេត និងសួរចម្លើយ មិនទាន់មានប្រសិទ្ធភាព។ ការប្រើអំពើទារុណកម្មដើម្បីបំណង

[1] *សូមមើល* Torture, en.wikipedia.org/wiki/Torture, p.1; M. Cherif Bassiouni, An Appraisal of Torture in International Practice: The Need for an International Convention for the Prevention and Suppression of Torture, 48 Revue Internationale de Droit Penal, p. 23 (M. Cherif Bassiouni, An Appraisal); J.H. Burgers, the Fight against Torture, 32 the Review of International Commission of Jurists 1984, p. 47; Andrew Byrnes, Torture and Other Offences Involving the Violations of the Physical or Mental Integrity of Human Persons, p. 197 in Substantive and Procedural Aspects of International Criminal Law: the Experience of International and National Courts, Gabrelle Kirk (ed.), 2000.

[2] *សូមមើល* Torture, *id*., section on historical methods of execution and capital punishment; Jan Skupinski, Prohibition of Torture and Other Inhuman Treatment, 15 Polish Yearbook of International Law, 164 (1986).

[3] *សូមមើល* Id., section on antiquity Torture, en.wikipedia.org/wiki/Torture; Winston P. Nagan and Lucie Atkins, the International Law of Torture: From Universal Proscription to Effective Application and Enforcement, 14 Harvard Human Rights Journal, 2001, p. 92; E188, Trial Chamber, ECCC, Judgement of Case 001, 26 July 2010, para. 252; David Chandler, Voices from S-21, 1999, p. 120.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

នេះ កើតមានជាច្រើនជាពិសេស ក្នុងអំឡុងសង្គ្រាមត្រជាក់ ដើម្បីបង្ក្រាបអ្នកប្រឆាំងរបបកុំម្មុយនីស្ត ឬរបបសេរីនិយម។[4] ព្រឹត្តិការណ៍នៃការបង្ក្រាបពួកកុំម្មុយនីស្ត តាមរយៈការធ្វើទារុណកម្ម កើតមាននៅក្នុងប្រទេស ឈីលី ក្រោមការដឹកនាំរបស់ លោក *Pinochet* ជាឧទាហរណ៍មួយយ៉ាងជាក់លាក់។[5] សម្ភារៈសម្រាប់ប្រើប្រាស់ជាច្រើន ត្រូវបានផលិត ដើម្បីធ្វើទារុណកម្ម។ វិធីធ្វើទារុណកម្ម (វាយប្រអប់បាតជើង) គ្មានបន្សល់នូវស្នាកស្នាម ដែលអ្នកគ្មានជំនាញ មិនអាចមើលដឹងថា វាជាអំពើទារុណកម្មក៏ត្រូវបានអភិវឌ្ឍ។[6] ខណៈដែលការធ្វើទារុណកម្មនាំឲ្យទទួលបានចម្លើយសារភាព ចម្លើយមួយចំនួនមិនពិតទេ។ អាជ្ញាធរអាចនឹងចាប់មនុស្សមិនមានកំហុស មកទទួលទោស ដោយសារតែការឆ្លើយដាក់ដោយជនដែលត្រូវបានគេធ្វើទារុណកម្ម។[7]

ដោយសារភាពគ្រោះថ្នាក់នៃអំពើទារុណកម្ម និងការប្រព្រឹត្តអំពើទារុណកម្មមានកំណើនកើនឡើង ក្របខណ្ឌច្បាប់ជាច្រើនត្រូវបានបង្កើតឡើង ទាំងកម្រិតជាតិ និងអន្តរជាតិ។ វាមានទម្រង់ជាឯកសារណែនាំ ឬសន្ធិសញ្ញា ដែលបង្កើតចេញជាកាតព្វកិច្ច។

ច្បាប់ជាតិជាច្រើន រាប់បញ្ចូលច្បាប់រដ្ឋធម្មនុញ្ញ បានហាមឃាត់អំពើទារុណកម្មជាយូរយារមកហើយ[8] ទោះបីជាមិនបានចែងច្បាស់នូវនិយមន័យអ្វីជាទារុណកម្ម[9] ឬបានចែងដោយផ្នែក មិនទាន់ស៊ីសង្វាក់គ្នាជាមួយនឹងនិយមន័យ កំណត់ក្នុងវិធានអន្តរជាតិក៏ដោយ។[10] ច្បាប់ទាំងនោះ បានចែងហាមឃាត់ជាដាច់ខាតនូវអំពើទារុណកម្ម។[11] ច្បាប់ខ្លះ មិនបានចែងរបៀបនេះទេ។[12] បន្ថែមពីលើនេះ ច្បាប់បាន ចែងនូវខ្លឹមសារជាច្រើន ពាក់ព័ន្ធការហាមឃាត់អំពើទារុណកម្ម ដូចជាការមិនអនុញ្ញាតឲ្យទទួលយកសំអាង "ការធ្វើ

---

[4] *សូមមើល* European Parliament Council adopted Regulation No. 1236/2005 on trade ban on torture implements.

[5] *សូមមើល* Military government of Chile (1973-1990), section on human rights violations, en.wikipedia.org /Military_government_of_Chile; William J. Aceves, the Anatomy of Torture, A Documentary History of *Filartiga v. Pena Irala*, 2007, p. 108; An Amnesty International Report, Torture in the Eighties, 1984, p. 150.

[6] *សូមមើល* Cherif Bassiouni, *supra* note 1, p. 32.

[7] *សូមមើល* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 26; torture, section on incrimination of innocent people, en.wikipedia.org/wiki/Torture; Chris Ingelse, the UN Committee against Torture, An Assessment, 2001, p. 29.

[8] *សូមមើល* Questionnaire on the Declaration on the Protection of All Persons from Being Subjected to Torture and Other Cruel , Inhuman or Degrading Treatment or Punishment, Report of the Secretary General, A/34/144, 21 September, 1979; torture, section on municipal law, en.wikipedia.org; the 1964 Constitution of Afghanistan, Article 26, *see* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 142; Hans Danelius, Article 5, in the Universal Declaration of Human Rights, A Commentary, Asbjorn Eide (ed.), 1992, p.101.

[9] *សូមមើល* The 1970 Constitution of People's Democratic of Yemen, Article 39, *see* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 149.

[10] *សូមមើល* Gail H. Miller, Defining Torture, 2005, p. 7.

[11] *សូមមើល* The 1965 Constitution of Honduras, Article 65, *see* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 163.

[12] *សូមមើល* The 1974 Constitution of Burma, Article 159 (a), *see* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 149.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ទារុណកម្មតាមបញ្ជារបស់ថ្នាក់លើ" ជាការដោះសាររួចខ្លួនពីការទទួលខុសត្រូវចំពោះអំពើទារុណកម្ម។[13] សហរដ្ឋអាមេរិកមានច្បាប់ជាតិចែងផ្តល់យុត្តាធិការដល់តុលាការក្នុងការពិចារណាបណ្តឹងអំពីអំពើទារុណកម្មប្រព្រឹត្តក្រៅដែនដីរបស់សហរដ្ឋអាមេរិកដោយជនបរទេស។[14]

ក្នុងកម្រិតអន្តរជាតិ មានឯកសារចែងហាមឃាត់អំពើទារុណកម្មជាច្រើន ដែលជាសេចក្តីប្រកាស[15] ឬជាសន្ធិសញ្ញា។[16] ឯកសារស្រដៀងគ្នាត្រូវបានបង្កើតផងដែរក្នុងកម្រិតតំបន់ ដូចជា ទ្វីបអឺរ៉ុប[17] និង អន្តរទ្វីបអាមេរិក (Inter-American Region)។[18] បន្ថែមពីលើក្របខណ្ឌច្បាប់ មានយន្តការអន្តរជាតិជាច្រើនសម្រាប់បង្ក្រាប និងបង្ការអំពើទារុណកម្ម។ យន្តការស៊ើបអង្កេតក្រោមអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម[19] មានលក្ខណៈពិសេសខុសពីយន្តការបង្កើតតាមអនុសញ្ញាសិទ្ធិមនុស្សដទៃទៀត ដែលគួរឲ្យកត់សំគាល់។ ថ្មីៗកន្លងទៅ អង្គការសហប្រជាជាតិបានអនុម័តពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ដោយបង្កើតនូវអនុគណៈកម្មាធិការចុះពិនិត្យមើលទីកន្លែងដកហូតសិទ្ធិសេរីភាពបុគ្គលក្នុងដែនដីរបស់រដ្ឋជាភាគី។[20]

ទាញចេញពីការបរិយាយខាងលើ យើងអាចសន្និដ្ឋានថា មានឯកសារហាមឃាត់អំពើទារុណកម្មសម្បូរបែប ទាំងក្នុងស្រុក និងនៅលើឆាកអន្តរជាតិ បង្កប់នូវភាពស៊ីសង្វាក់គ្នា ក្នុងការហាមឃាត់អំពើទារុណកម្ម បន្ថែមពីលើយន្តការដ៏សម្បូរបែបកម្រិតតំបន់ និងពិភពលោក សម្រាប់បង្ក្រាប និងបង្ការអំពើទារុណកម្ម។[21] នេះបង្ហាញថា ពិភពលោកទាំងមូលមិនអត់អោនចំពោះអំពើទារុណកម្មទេ។ ការហាមឃាត់មានជាយូរយារ និងទូទាំងពិភពលោក ដែលនាំឲ្យវិធាននៃការហាមឃាត់អំពើទារុណកម្មក្លាយជា

---

[13] *សូមមើល* Bill for the Penal Punishment of Torture, Article 4, Torture and Other Cruel, Inhuman or Degrading Treatment or Punishment, Report of the Secretary-General, Addendum, A/39/499/Add.1, 24 October 1984, p. 7.

[14] *សូមមើល* The Alien Tort Claims Act, *see* Gail H. Miller, *supra* note 10, pp. 29 and 31; William J. Aceves, the Anatomy of Torture, *supra* note 5, p. 78; see generally Craig Scott ed., Torture as Tort, 2001; United States, *Court of Appeals, Filartiga v. Pena-Irala*, International Law Reports, Vol. 77, 1988, p. 169.

[15] *សូមមើល* Declaration on the Protection of All Persons from Being Subjected to Torture and Other Cruel, Inhuman or Degrading Treatment or Punishment, GA Resolution 3452 (XXX) of 9 December 1975.

[16] *សូមមើល* Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment, the Raoul Wallenberg Institute Compilation of Human Rights Instruments, 3rd Ed., 2012, p. 638.

[17] *សូមមើល* Convention for the Protection of Human Rights and Fundamental Freedoms, the Raoul Wallenberg Institute Compilation of Human Rights Instruments, 3rd Ed., 2012, p. 103.

[18] *សូមមើល* American Convention on Human Rights, the Raoul Wallenberg Institute Compilation of Human Rights Instruments, 3rd ed., 2012, p. 183.

[19] *សូមមើល* Torture Convention, *supra* note 16, Article 20.

[20] *សូមមើល* Optional Protocol to the Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment, GA Resolution 57/199 of 18 December 2002, UN TS, vol. 2375, No.A-24841.

[21] *សូមមើល* Roland Bank, International Efforts to Combat Torture and Inhuman Treatment: Have the New Mechanisms Improved Protection? 8 (4) European Journal of International Law, 1997; Mark Kelly, Perspectives from the European Committee for the Prevention of Torture and Inhuman or Degrading Treatment or Punishment, 21 (8) Human Rights Law Journal (2000); Malcolm D Evans, Getting to Grips with Torture, 51 International and Comparative Law Quarterly 2002.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

វិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[22] វិធានការហាមឃាត់បានវិវត្តមកជាការបង្ការជាជាងឆ្លើយតបចំពោះអំពើទារុណកម្ម ដែលបានកើតឡើងរួចមកហើយ។ នេះ ប្រសិនបើយើងពិនិត្យមើលគោលបំណងនៃយន្តការស៊ើបអង្កេត និងការបង្កើតអនុគណៈកម្មាធិការ។ និន្នាការចង់បានការបង្ការនេះ ដោយសារការកើតអំពើទារុណកម្ម វាដូចជាបាយឆ្អិនរួចទៅហើយ ដែលមិនអាចក្លាយជាអង្ករវិញបានទេ។ ជនរងគ្រោះនៃអំពើទារុណកម្មទទួលរងទុក្ខទោសធ្ងន់ធ្ងរ (មានTrauma) ដែលមិនអាចមានវិធីព្យាបាលឲ្យជនរងគ្រោះមានសភាពដូចដើមវិញឡើយ។[23]

### ២.១. និយមន័យ

ដូចដែលបានសរសេររៀបរាប់ខាងលើ មានឯកសារហាមឃាត់អំពើទារុណកម្មជាច្រើន ទោះបីជាយ៉ាងនេះក្តី មានតែអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ឆ្នាំ ១៩៨៤ ទេ ដែលបានចែងន័យរបស់ទារុណកម្មលម្អិត និងជាក់លាក់ជាងគេ។ មាត្រា ១ បានចែងថា៖

> *ទារុណកម្មជា " អំពើណាមួយ ដែលតាមរយៈនេះ ការឈឺចាប់ ឬការទទួលរងធ្ងន់ធ្ងរ ត្រូវបានប្រព្រឹត្តឡើងដោយចេតនា ទៅលើបុគ្គលណាម្នាក់ ក្នុងគោលបំណងដូចជា ទទួលបានពីបុគ្គលនោះ ឬមនុស្សទីបី នូវព័ត៌មាន ឬចម្លើយសារភាព ដើម្បីផ្តន្ទាទោសបុគ្គលនោះ ចំពោះអំពើ ដែលគាត់ ឬមនុស្សទីបី បានប្រព្រឹត្ត ឬត្រូវបានសង្ស័យថាបានប្រព្រឹត្ត ឬដើម្បីបំភ័យ ឬបង្ខំគាត់ ឬមនុស្សទីបី ឬសម្រាប់ហេតុផលណាមួយ ផ្អែកលើការរើសអើងប្រភេទណាមួយ នៅពេលដែលការឈឺចាប់ ឬការទទួលរងនោះ ត្រូវបានប្រព្រឹត្តដោយ ឬជំរុញដោយ ឬជាមួយការយល់ព្រម ឬយល់ព្រមដោយស្ងាត់ស្ងៀម (acquiescence) របស់មន្ត្រីសាធារណៈ ឬបុគ្គលដទៃ ដែលដើរតួនាទីជាមន្ត្រីសាធារណៈ។ វាមិនរាប់បញ្ចូលនូវការឈឺចាប់ ឬការទទួលរងដែលគ្រាន់តែកើតមកពី និងភ្ជាប់មកជាមួយនឹងទណ្ឌកម្មស្របច្បាប់។*[24]

ទារុណកម្មជាអំពើ ឬការខកខាន ឬហៅម្យ៉ាងទៀតថាជា អំពើសកម្ម ឬអំពើអកម្ម (ដូចជាការមិនផ្តល់អាហារដោយអាជ្ញាធរ តាមកាតព្វកិច្ចតម្រូវ) ដែលបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរផ្លូវកាយ និងផ្លូវចិត្ត។ វាអាចជាអំពើបង្ករបួសស្នាមមើលឃើញជាក់ស្តែង។ វាអាចជាអំពើបង្ខំឲ្យអ្នកទោសដើរគ្មានឈប់សំរាកក្នុងបន្ទប់ ឬបំពងសំឡេងរំខានមិនឲ្យជនជាប់ឃុំឃាំងសម្រាកបាន។ វាក៏អាចជាទង្វើខកខានមិនបំពេញ

---

[22] *សូមមើល* J.Herman Burgers & Hans Danelius, *supra* note 1, p. 120; Gail H. Miller, *supra* note 10, p. 3; for the details meaning of the customary international law in Khmer, *see* Dr. MEAS Bora, customary international law, 2012, available at the library of the Cambodian University for Specialties.

[23] *សូមមើល* The International Fight against Torture, Antonio Cassese (ed.), 1991, p. 15.

[24] *សូមមើល* The Torture Convention, *supra* note 16.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

កាតព្វកិច្ចណាមួយ។ ឧទាហរណ៍ មន្ត្រីពន្ធនាគារមានកាតព្វកិច្ចផ្តល់អាហារដល់ជនជាប់ឃុំឃាំង តែមិនផ្តល់អាហារដោយចេតនា ធ្វើឲ្យជននោះរងការឈឺចាប់ធ្ងន់ធ្ងរ។ ការឈឺចាប់អាចកើតមានចំពោះផ្លូវចិត្ត ឧទាហរណ៍ ការសម្លុតគំរាមសម្លាប់ ដែលធ្វើឲ្យបុគ្គលណាមួយភិតភ័យ និងឈឺចាប់។ ការឈឺចាប់ប្រភេទនេះ មិនអាចត្រូវបានមើលឃើញដោយមនុស្សគ្មានជំនាញទេ។ អនុសញ្ញាប្រឆាំងអំពើទារុណកម្មខុសពីអនុសញ្ញាដទៃទៀត ដោយសារអនុសញ្ញាប្រឆាំងអំពើទារុណកម្មចែងច្បាស់អំពីការឈឺចាប់ផ្លូវចិត្ត។[25] ពាក់ព័ន្ធជាមួយនឹងកម្រិតនៃការឈឺចាប់ ការពិចារណាត្រូវធ្វើឡើងទៅតាមករណីនីមួយៗ ដោយពិចារណាកត្តាជាច្រើន។ ជាក់ស្តែង ទង្វើដូចគ្នារបស់បុគ្គលមួយទៅលើមនុស្សពេញវ័យ និងចាស់ជរា នាំឲ្យមានកម្រិតឈឺចាប់ខុសគ្នា។ មានការស្នើថា ដើម្បីពិចារណាថា អំពើណាមួយជាទារុណកម្ម ឬមិនមែន ត្រូវពិចារណានូវកត្តាមួយចំនួន ដូចជា រយៈពេលនៃការប្រព្រឹត្ត ផលវិបាករូបរាងកាយដោយសារអំពើប្រព្រឹត្ត ផលវិបាកផ្លូវចិត្តនៃអំពើប្រព្រឹត្ត ភេទ អាយុ ស្ថានភាពសុខភាពរបស់ជនរងគ្រោះ។[26]

អំពើទារុណកម្ម អាចត្រូវបានធ្វើឡើងដោយអាជ្ញាធររដ្ឋ ឬចូលរួមដោយប្រយោលតាមរយៈការផ្តល់ការយល់ព្រម ឬការទទួលយកអំពើទារុណកម្មដោយស្ងាត់ស្ងៀម (Acquiescence[27]) ឬប្រព្រឹត្តដោយក្រុមជនស៊ីវិលដើរតួនាទីដូចជារដ្ឋ (private people acting as officials)។ ប្រទេសមួយចំនួនបានធ្វើឯកជនរូប- នីយកម្ម ការគ្រប់គ្រងពន្ធនាគារដល់ក្រុមហ៊ុនឯកជន។ ក្នុងដំណើរការនៃការគ្រប់គ្រង ឆ្មាំគុកក្រុមហ៊ុនឯកជន អាចធ្វើអំពើទារុណកម្មជនជាប់ឃុំឃាំង។ អាជ្ញាធរដឹង តែមិនចាត់ការបង្ក្រាប នឹងត្រូវបានចាត់ទុកថាទទួលយកនូវអំពើនេះ ដែលនាំឲ្យមានការទទួលខុសត្រូវរបស់រដ្ឋ។ ក្នុងរដ្ឋមួយ សង្គ្រាមស៊ីវិលបានធ្វើឲ្យរដ្ឋាភិបាលបាត់បង់អំណាចគ្រប់គ្រងក្រុមមនុស្សដែលមានអំណាចជាងគេ មានរចនាសម្ព័ន្ធគ្រប់គ្រង អាចប្រមូលពន្ធបាន។ អំពើទារុណកម្មប្រព្រឹត្តដោយក្រុមនេះ អាចត្រូវបានចាត់ថា ជាអំពើទារុណកម្ម ដែលស្ថិតចូលក្នុងនិយមន័យនៃអំពើទារុណកម្មក្នុងមាត្រា១។[28] អ្នកសិក្សាគួរកត់សំគាល់ផងដែរថា ន័យនៃពាក្យ "ទារុណកម្ម" ក្រោមលិខិតូបករណ៍អន្តរជាតិដទៃទៀតរាប់បញ្ចូលអំពើធ្វើដោយបុគ្គលស៊ីវិលផងដែរ។[29]

ការប្រព្រឹត្តត្រូវតែមានបំណង ដូចជា ដើម្បីបានចម្លើយសារភាពជាដើម។ ការតម្រូវរបៀបនេះ ជាការឆ្លើយតបការធ្វើទារុណកម្ម ក្នុងអំឡុងពេលសង្គ្រាមត្រជាក់។ អ្នកស្រាវជ្រាវគួរកត់សំគាល់ថា ក្រោម

[25] *សូមមើល* Psychological torture are, for example, verbal abuse, threat of death, surveillance at work, mock executions, *see* Antonio Cassese (ed.), *supra* note 23, p. 16.

[26] *សូមមើល* Lene Wendland, Association for the Prevention of Torture, A Handbook on State Obligations under the UN Convention against Torture, 2002, p. 26.

[27] *សូមមើល* Dr. MEAS Bora, customary international law, *supra* note 22, p. 11.

[28] *សូមមើល* *Elmi v. Australia*, Communication 120/1998, U.N. Doc. CAT/C/22/D/120/1998 (May 14, 1999), paras. 6.2, 6.5.

[29] *សូមមើល* Article 3 of the European Convention, *supra* note 17.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាដូ

អនុសញ្ញាដ៏ទៃទៀត បំណងមិនត្រូវបានចែងទាមទារឡើយ។[30]មាត្រា ១ នៃអនុសញ្ញា បានចែងថាអំពើមួយចំនួន ដូចជាទណ្ឌកម្មអនុញ្ញាតដោយច្បាប់ជាតិ មិនមែនជាអំពើទារុណកម្មទេ។ មានករណីក្តីក្តាំមួយបានកើតមានឡើងពាក់ព័ន្ធជាមួយនឹង ការបញ្ជូនស្ត្រីជនជាតិ Iran ចេញពីប្រទេសជប៉ុន ដែលនឹងនាំឲ្យមានការរំលោភមាត្រា ៣ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ដែលជប៉ុនជាភាគី។ អាជ្ញាធរប្រទេសជប៉ុនទទួលស្គាល់ថា ស្ត្រីនោះត្រូវបានចោទពីបទផិតក្បត់ក្នុងប្រទេស Iran ដែលនឹងអាចទទួលទោសប្រហារជីវិត ដោយគប់ដុំថ្មលើខ្លួនប្រាណ (Stoning to Death) ក៏ប៉ុន្តែ បានអះអាងថា ទណ្ឌកម្មនេះអនុញ្ញាតដោយច្បាប់ Iran ដូចនេះ មិនមែនជាទារុណកម្មចែងតាមមាត្រា ១ ទេ។ ការបញ្ជូនស្ត្រី ទៅជួបទណ្ឌកម្មប្រភេទនេះ ជប៉ុនមិនខុសកាតព្វកិច្ច ក្រោមមាត្រា ៣ឡើយ។[31] ទណ្ឌកម្មប្រភេទនេះ ពិតជាមានការឈឺចាប់ធ្ងន់ធ្ងរ និងសាហាវយង់ឃ្នងណាស់។ ការបកស្រាយអ្វីជាអំពើមិនមែនទារុណកម្ម មិនគួរអនុលោមតាមតែច្បាប់ជាតិតែប៉ុណ្ណោះទេ តែត្រូវពិចារណានូវវិធានអន្តរជាតិផង។ បន្ថែមពីលើនេះ ការបកស្រាយមាត្រា ១ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ត្រូវបកស្រាយក្នុងបរិបទនៃគោលបំណងនៃអនុសញ្ញា។[32] ទោះបីជាទណ្ឌកម្មប្រភេទនេះ មិនខុសមាត្រា ១ តែវាខុសនឹងមាត្រាផ្សេងនៃកតិកាសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។[33]

### ២.២. អំពើទារុណកម្ម និងអំពើប្រព្រឹត្តដទៃទៀត

អនុសញ្ញាពាក់ព័ន្ធជាច្រើន បានចែងចាត់ប្រភេទនៃអំពើផ្សេងៗ ទោះបីពាក្យពេជន៍ ដែលត្រូវបានប្រើប្រាស់ ខុសគ្នាបន្តិចបន្តួចក្តី។[34] អំពើត្រូវបានចាត់ជាទារុណកម្មអមនុស្សធម៌ បន្ទាបបន្ថោកជាដើម។ អំពើអមនុស្សធម៌ អាចជាអំពើដែលគេគួរប្រព្រឹត្តលើសត្វ មិនមែនលើមនុស្ស។ ឧទាហរណ៍ ការបង្ខំឲ្យអ្នកទោសផឹកទឹកនោមខ្លួនឯងគឺជាអំពើអនុស្សធម៌។ អំពើបន្ទាបបន្ថោក អាចជាអំពើ ធ្វើឲ្យបុគ្គលណាម្នាក់មានភាពខ្មាស់អៀន ដូចជា ការបង្ខំជនជាប់ឃុំបណ្តោះអាសន្ន ពាក់អាវរបស់ទណ្ឌិត ការដាក់ឃ្នោះដៃអ្នកទោសជិះតាមរថយន្ត កាត់ទីសាធារណៈ ដោយមិនចាំបាច់ជាដើម។ នេះគ្រាន់តែជាសញ្ញាណតែប៉ុណ្ណោះ ការចែកឲ្យដាច់ស្រឡះរវាងអំពើទាំងនេះ ពិតជាមានការលំបាក។ លក្ខខណ្ឌឃុំឃាំងក្នុងពន្ធនាគារ អាចឈានទៅដល់ការប្រព្រឹត្តអមនុស្សធម៌។[35]

---

[30] *សូមមើល* International Covenant on Civil and Political Rights (ICCPR), GA Resolution 2200 A (XXI) of 16 December 1966, UNTS, vols. 999, No.I-14668, Article 7.

[31] *សូមមើល* See MEAS Bora, the Evolution of the Principle of *Non-Refoulement* with Special Reference to the Prevention of Torture (Ph.D. thesis), 2007, p. 105.

[32] *សូមមើល* Association of the Pprevention of Torture, Definition of torture, proceedings of an expert seminar, 10-11 November 2001, p. 20.

[33] *សូមមើល* ICCPR, *supra* note 30; Compilation of General Comments and General Recommendations Adopted by the Human Rights Treaty Bodies, HRI/GEN/1/Rev.9 (Vol.I), 2008, General Comment No. 7 : Article 7, p. 178.

[34] *សូមមើល* Article 3 of the European Convention on Human Rights does not use term “cruel”; however, Article 7 of the ICCPR used.

[35] *សូមមើល* DJ Harris, Law of the European Convention on Human Rights, 1995, p. 66.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ភាពខុសគ្នានៃប្រភេទអំពើ ត្រូវបានចង្អុលបង្ហាញដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ក្នុងរឿងក្ដីរបស់ Ireland ប្រឆាំងជាមួយនឹងចក្រភពអង់គ្លេស។ បណ្ដឹងបានធ្វើឡើងដោយសារ អាជ្ញាធរអង់គ្លេស ប្រើប្រាស់វិធីសួរចម្លើយចំនួនប្រាំប្រភេទលើជនជាតិ Ireland ដែលជាជនសង្ស័យនៃអំពើភេរវកម្ម ដើម្បីទទួលបានចម្លើយសារភាព និងផ្អែកលើគោលការណ៍ចាំបាច់ (State of Necessity)។ គណៈកម្មការសិទ្ធិមនុស្សអ៊ឺរ៉ុប និងតុលាការ មានយោបល់ផ្ទុយគ្នា។ ខណៈដែលគណៈកម្មការយល់ថា អំពើនោះជាអំពើទារុណកម្ម និងអំពើអមនុស្សធម៌[36] តុលាការចាត់ថា គ្រាន់តែជាអំពើអមនុស្សធម៌។[37] យ៉ាងនេះក្ដី សាលក្រមបានជួយស្រាយបំភ្លឺនូវបញ្ហាមួយចំនួនពាក់ព័ន្ធជាមួយនឹងអត្ថន័យនៃពាក្យ "ទារុណកម្ម" និងភាពខុសគ្នាជាមួយអំពើដទៃទៀត។ ទារុណកម្ម សំដៅលើអំពើដែលបង្កការឈឺចាប់ធ្ងន់ធ្ងរផ្ទុយពីអំពើមនុស្សធម៌ ដែលមិនទាមទារការឈឺចាប់របៀបនេះ។[38] ទោះបីជាយ៉ាងនេះក្ដី អំពើអមនុស្សធម៌ ក៏ត្រូវហួសពីកម្រិតឈឺចាប់ធម្មតាដែលមនុស្សទូទៅយោគយល់។[39] ការកំណត់កម្រិតឈឺចាប់នេះ ជាការសំខាន់ សម្រាប់បែងចែកអ្វីដែលជាអំពើទារុណកម្ម អំពើអមនុស្សធម៌ និងអំពើដទៃទៀត ដែលមិនចូលក្នុងប្រភេទទាំងពីរនេះ។

ភាពច្បាស់លាស់មួយទៀត គឺថាគ្រប់អំពើទារុណកម្មសុទ្ធតែជាអំពើអមនុស្សធម៌។[40] តុលាការប្រកាន់ជំហរថា ទាំងការហាមឃាត់ទារុណកម្ម និងអំពើអមនុស្សធម៌សុទ្ធតែមានចរិតដាច់ខាត ក្រោមមាត្រា ៣នៃកតិកាសញ្ញាអ៊ឺរ៉ុបស្ដីពី សិទ្ធិមនុស្ស។[41] វាជាគំនិតមួយទទួលយកបាន ដោយសារ គេមានការពិបាកញែកអំពើទារុណកម្មចេញពីអំពើមនុស្សធម៌។ អនុសញ្ញាកម្រិតសាកល និងគណៈកម្មាធិការសិទ្ធិមនុស្សអន្តរ-ជាតិ របស់អង្គការសហប្រជាជាតិ នៅមានភាពមិនស៊ីសង្វាក់គ្នានៅឡើយ ក្នុងការប្រកាន់ជំហរថា អំពើអមនុស្សធម៌ត្រូវតែបានហាមឃាត់ជាដាច់ខាត។ នេះ ប្រហែលជាបណ្ដាលមកពីបរិបទនៃប្រទេសមួយចំនួនក្នុងទ្វីបអាស៊ី ដែលនៅមានការយោគយល់ចំពោះអំពើប្រព្រឹត្តមួយចំនួនដែលមិនធ្ងន់ធ្ងរ។

### ២.៣. កាតព្វកិច្ចពាក់ព័ន្ធជាមួយការហាមឃាត់អំពើទារុណកម្ម

មានកាតព្វកិច្ចជាច្រើន ចែងយ៉ាងច្បាស់ក្នុងអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ឆ្នាំ ១៩៨៤។ ផ្នែកនេះលើកយកបរិយាយនូវកាតព្វកិច្ចពីរប្រភេទ។

---

[36] *សូមមើល* P. van Dijk and G.J.H. van Hoof, Theory and Practice of the European Convention on Human Rights, 1984, Article 3, p. 192.

[37] *សូមមើល* *Ireland v UK*, (1978), ECHR. (Series A) No. 25, section 167; Debra Long, Association of the Prevention of Torture, Guide to Jurisprudence on Torture and Ill-treatment, 2002, p. 14

[38] *សូមមើល* Harris, O'Boyle and Warbrick, Law of the European Convention on Human Rights, 2nd ed., 2009, p. 73.

[39] *សូមមើល* Id.; APT, definition of torture, *supra* note 32, p. 26.

[40] *សូមមើល* Torture is an aggravated and deliberate form of cruel, inhuman or degrading treatment or punishment, *see* Ahcene Boulesbaa, the U.N. Convention on Torture and the Prospects for Enforcement, 1999, p. 8

[41] *សូមមើល* Harris, O'Boyle and Warbrick, *supra* note 38, p. 69.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

### ២.៣.១. កាតព្វកិច្ចបង្ការ

វាជាប្រភេទកាតព្វកិច្ចមធ្យោបាយ (Obligation of Conduct) ដូចជាការតម្រូវឲ្យធ្វើច្បាប់ថ្មី (ធ្វើច្បាប់ចាត់អំពើទារុណកម្មជាបទឧក្រិដ្ឋមានទោសធ្ងន់ធ្ងរ)[42] ឬកែច្បាប់ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម។ អនុសញ្ញាបានចែងបង្គាប់ឲ្យមាន ការបណ្តុះបណ្តាល មន្ត្រីអនុវត្តច្បាប់នូវខ្លឹមសារអនុសញ្ញា[43] រៀបចំយន្តការគ្រប់គ្រងពន្ធនាគារឲ្យបានល្អ អនុញ្ញាតឲ្យមានបណ្តឹងអំពីទារុណកម្មរបស់ជនរងគ្រោះ និងដោះស្រាយមានប្រសិទ្ធភាព[44] បង្កើតស្ថាប័នឯករាជ្យ ចុះធ្វើអធិការកិច្ចពន្ធនាគារ ដើម្បីបង្ការអំពើទារុណកម្ម។[45] នេះជាកាតព្វកិច្ចបង្កាទារុណកម្មកុំឲ្យកើតមានក្នុងស្រុក។ រដ្ឋមានកាតព្វកិច្ចបង្ការទារុណកម្មកើតនៅក្រៅដែនដីរបស់ខ្លួនផងដែរ តាមរយៈការមិនបញ្ជូនជនណាមួយទៅជួបគ្រោះថ្នាក់ដោយសារអំពើទារុណកម្មនៅក្រៅប្រទេស។[46]

### ២.៣.២. កាតព្វកិច្ចក្រោយអំពើទារុណកម្មបានកើតមានឡើង

វាជាប្រភេទកាតព្វកិច្ចលទ្ធផល (Obligation of Result) ទាមទារឲ្យមានដំណោះស្រាយមានប្រសិទ្ធភាព (Effective Remedy)។[47] មានន័យថា នៅពេលមានអំពើទារុណកម្មកើតមានឡើង ជនប្រព្រឹត្តត្រូវទទួលទោសដោយគ្មានលើកលែង ហើយជនរងគ្រោះទទួលបានសំណងសមស្របពិតប្រាកដ។ ក្នុងដំណើរការឈានទៅសម្រេចគោលបំណងនេះ អាជ្ញាធរត្រូវធ្វើការងារសកម្មចេញពីការផ្តួចផ្តើមរបស់ខ្លួនស៊ើបអង្កេតជាបន្ទាន់ និងអព្យាក្រិត្យ រួចបញ្ជូនសំណុំរឿងទៅតុលាការ។[48]

អ្នកគ្រប់គ្នាដឹងថាអំពើទារុណកម្មជាអំពើខុសច្បាប់ ដូចនេះធ្វើទារុណកម្ម ច្រើនតែត្រូវបានប្រព្រឹត្តក្នុងទីកន្លែងសម្ងាត់ ដូចជាក្នុងស្ថានីយ៍ប៉ូលីស ជាមួយការគម្រាមគំហែងជនរងគ្រោះមិនឲ្យរាយការណ៍។[49] ដូចនេះ វាជាការមិនអាចទៅរួចបានទេ ក្នុងការតម្រូវឲ្យជនរងគ្រោះប្រគល់ភស្តុតាងគ្រប់គ្រាន់បង្ហាញថាមានអំពើទារុណកម្មកើតមានចំពោះខ្លួន មុននឹងអាជ្ញាធរចាប់ផ្តើមស៊ើបអង្កេត។ ក្នុងករណីខ្លះ ស្នាកស្នាមទារុណកម្មត្រូវបានរលប់ដោយសារការព្យាបាលរបស់អាជ្ញាធរ ដែលធ្វើអំពើទារុណកម្ម។ ព័ត៌មានស្តីពីទារុណកម្មក្នុងទំព័រសារព័ត៌មានជាការគ្រប់គ្រាន់រួចទៅហើយ នាំឲ្យមានការស៊ើបអង្កេតដោយអាជ្ញាធរជាបន្ទាន់ ដើម្បីកុំឲ្យបាត់ស្នាកស្នាម ឬភស្តុតាងអំពើទារុណកម្ម។

---

[42] *សូមមើល* The Torture Convention, *supra* note 16, Art. 4.

[43] *សូមមើល* *Id.*, Art. 10.

[44] *សូមមើល* *Id.*, Arts. 13 and 14.

[45] *សូមមើល* 2002 Optional Protocol to the Torture Convention, *supra* note 20, Art. 17.

[46] *សូមមើល* The Torture Convention, *supra* note 16, Art. 3.

[47] *សូមមើល* The Universal Declaration of Human Rights, GA Resolution 217A (III) of 10 December 1948.

[48] *សូមមើល* This obligation is required regardless numbers of acts of torture.

[49] *សូមមើល* M. Cherif Bassiouni, An Appraisal, *supra* note 1, p. 33.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាដូ

ជាទូទៅ ព្រះរាជអាជ្ញាជាអ្នកពិនិត្យ និងគ្រប់គ្រងពន្ធនាគារ។ ការតម្រូវឲ្យព្រះរាជអាជ្ញា ស៊ើបអង្កេតករណីទារុណកម្ម កើតមានក្នុងពន្ធនាគារ និងមិនមានលទ្ធផលគួរឲ្យទុកចិត្តបានទេ ពីព្រោះការពិតអាចនឹងនាំឲ្យមានការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាខ្លួនឯង ដោយសារការខកខានមិនបានពិនិត្យមើលពន្ធនាគារឲ្យបានដិតដល់ នាំឲ្យមានអំពើទារុណកម្មដោយមន្ត្រីក្រោមបង្គាប់។

នៅពេលសំណុំរឿងដល់ដៃតុលាការ តុលាការត្រូវវិនិច្ឆ័យសេចក្តីឲ្យបានឆាប់ និងចេញនូវសំណងជាក់ស្តែង អាចជាសំណងលុយកាក់ ផ្លូវចិត្ត និងកម្មវិធីស្តារកាយសម្បទាជាដើម។ ចំណុចខាងក្រោយនេះទាមទារឲ្យមាន ដោយសារ ជនរងគ្រោះនៃអំពើទារុណកម្មទទួលរងនូវការឈឺចាប់ខ្លាំង មានការប៉ះទង្គិចធ្ងន់ធ្ងរ តម្រូវឲ្យមានការព្យាបាលផ្លូវចិត្ត។ សំណងនេះ ត្រូវតែពិតប្រាកដ ក្នុងន័យថា ត្រូវតែយកទៅអនុវត្តចេញជាផ្លែផ្កា មិនគ្រាន់តែចែងក្នុងសាលក្រមតែប៉ុណ្ណោះទេ។[50] តុលាការអាចដោះលែងជនជាប់ចោទ ជាជនរងគ្រោះនៃអំពើទារុណកម្ម ដោយអាជ្ញាធរផ្អែកតាមទ្រឹស្តីនៃការបំពាននីតិវិធី (Abuse of Process[51])។

កាតព្វកិច្ចចំពោះទារុណកម្ម ដែលកើតមានរួចហើយ អនុវត្តផងដែរចំពោះទារុណកម្ម ដែលកើតនៅទីណាក៏ដោយ។ អនុសញ្ញាប្រឆាំងអំពើទារុណកម្ម ទាមទារឲ្យរដ្ឋជាភាគីធ្វើច្បាប់ផ្តល់យុត្តាធិការដល់តុលាការជាតិកាត់ទោសជនសង្ស័យប្រព្រឹត្តអំពើទារុណកម្មក្រៅដែនដីរដ្ឋ ដែលមានវត្តមានក្នុងដែនដីហើយ មិនធ្វើបត្យាប័នបញ្ជូនជននោះទៅទទួលការកាត់ទោសក្នុងប្រទេសណាមួយទេ។[52] ករណីប្តឹងដោយ *Belgium* ប្រឆាំងនឹង *Senegal* ក្នុងរឿងលោក *Habre* ពាក់ព័ន្ធកាតព្វកិច្ចប្រភេទនេះ។[53] ទ្រឹស្តីជាមូលដ្ឋាននៃកាតព្វកិច្ចប្រភេទនេះ គឺយុត្តាធិការសាកល (Universal Jurisdiction[54])។ កាតព្វកិច្ចនេះ តម្រូវដល់រដ្ឋ ដើម្បីធានាថា មិនមានទីកន្លែងមានសុវត្ថិភាពសម្រាប់ជនប្រព្រឹត្តអំពើទារុណកម្មឡើយ។ វាទាមទារឲ្យរដ្ឋ សហការគ្នាជួយគ្នាដើម្បីកាត់ទោស ដូចជាប្រគល់ជនសង្ស័យ ភស្តុតាង ជាដើម។[55]

ប្រសិនបើពិចារណាកាតព្វកិច្ចចំបងពីរប្រភេទនេះ កាតព្វកិច្ចឆ្លើយតបចំពោះអំពើទារុណកម្មកើតមានរួចហើយ មានភាពស្មុគស្មាញ ចំណាយពេលវេលា និងធនធានច្រើន។ វាតម្រូវឲ្យមានយន្តការពាក់ព័ន្ធធ្វើការងារប្រកបដោយប្រសិទ្ធភាព បានឆាប់រហ័ស សម្របសម្រួលមានប្រសិទ្ធភាព មានធនធានមនុស្ស

---

[50] *សូមមើល* CAT/C/SR.294/Add.1, para.23; Human Rights Committee, General Comment No. 31: the Nature of the General Legal Obligation Imposed on States Parties to the Covenant, HRI/GEN/1/Rev. 9(Vol. I), 2004, para. 16.

[51] *សូមមើល* The Office of Co-Investigating Judges, Order of Provisional Detention, C3/10, 31 July 2007, para. 21.

[52] *សូមមើល* The Torture Convention, *supra* note 16, Arts. 5, 7.

[53] *សូមមើល* ICJ, Questions Relating to the Obligation to Prosecute or Extradite (*Belgium v. Senegal*), judgment 20 July 2012, p.6.

[54] *សូមមើល* Georges Abi-Saab, the Proper Role of Universal Jurisdiction, 1 journal of International Criminal Justice (2003); Luc Reydams, Belgium's First Application of Universal Jurisdiction: the *Butare Four* Case, 1 Journal of International Criminal Justice (2003); Roger O'Keefe, the Grave Breaches Regime and Universal Jurisdiction, 7 JICJ (2009), p. 830; Louise Arbour, Will the ICC Have an Impact on Universal Jurisdiction, 1 JICJ (2003).

[55] *សូមមើល* The Torture Convention, *supra* note 16, Art. 9.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

និងក្របខណ្ឌច្បាប់គ្រប់គ្រាន់។ ប្រសិនបើ ចំណែកណាមួយនៃដំណើរការមិនមានលទ្ធផលល្អ ឬរាំងស្ទះ ឧទាហរណ៍ ប៉ូលីសមិនបានធ្វើការងារអង្កេតដោយឯករាជ្យ វានឹងមិនអាចនាំឲ្យមានដំណោះស្រាយមានប្រសិទ្ធភាពទេ។ ការអាក់ខាន សូម្បីផ្នែកតែមួយ ក៏នាំឲ្យមានការទទួលខុសត្រូវរបស់រដ្ឋដែរ។[56] ជាសរុប ការងាកមករកការបង្ការជាជាងព្យាបាល ពិតជាទង្វើមួយមានសារៈសំខាន់ និងចាំបាច់មិនអាចខ្វះបាន។

### ២.៤. ចរិតនៃការហាមឃាត់

ការហាមឃាត់អំពើទារុណកម្មត្រូវមានជាដាច់ខាតគ្រប់កាលៈទេសៈ ទោះបីក្នុងពេលមានសង្គ្រាម ឬសន្តិភាពក្តី ក្នុងលិខិតូបករណ៍អន្តរជាតិ។[57] នៅក្នុងពេលមានសង្គ្រាម ឬស្ថានភាពគ្រោះអាសន្នសាធារណៈ ជាធម្មតា តុលាការស៊ីវិលមិនមានដំណើរការទេ។ តុលាការយោធាមានដំណើរការសកម្ម ហើយអាជ្ញាធរយោធា ឬប៉ូលីសអាចនឹងមានអំណាចច្រើនតាមច្បាប់ ខុសពីពេលមិនមានគ្រោះអាសន្ន។ អាជ្ញាធរទាំងនេះ ជាទូទៅ ដើម្បីទប់ស្កាត់ការកុំឲ្យរីករាលដាល នឹងប្រើប្រាស់គ្រប់វិធានការ ដូចជាការចាប់ ខ្លួនមនុស្ស ឬអាចធ្វើអំពើទារុណកម្មយកចម្លើយ[58] ដែលអាចនាំឲ្យមានការចាប់ខ្លួនអ្នកមិនប្រព្រឹត្តខុស។ ជាការឆ្លើយតប ប្រជាពលរដ្ឋអាចនឹងមានការតបត នាំឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ ដោយសារជនស្លូតត្រង់ត្រូវបានគេបំពារបំពាន។ នេះហើយជាមូលហេតុមួយ ដែលនាំឲ្យមានការហាមឃាត់អំពើទារុណកម្មជាដាច់ខាត ទោះបីប្រទេសស្ថិតនៅក្នុងពេលមានសង្គ្រាមក្តី។

តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ក្នុងករណីក្តីក្តាំរបស់ *Soering* អះអាងថា ការហាមឃាត់អំពើ ទារុណកម្មជាតម្លៃសំខាន់របស់ទ្វីបអ៊ឺរ៉ុប។[59] អ្នកស្រាវជ្រាវ និងស្ថាប័នអន្តរជាតិ បានឯកភាពថា ការហាមឃាត់អំពើទារុណកម្ម ជាវិធានមានឋានៈខ្ពស់បំផុតក្នុងចំណោមវិធាននៃច្បាប់អន្តរជាតិ (*Jus cogens* / *perem-ptory norm*[60])។

ភាពដាច់ខាតនៃការហាមឃាត់អំពើទារុណកម្ម មានន័យថាជាការមិនទទួលយកលេស ឬយុត្តិកម្មណាមួយ ដើម្បីនាំឲ្យមានការរួចផុតពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើទារុណកម្ម។ អំណះ-អំណាងរបស់អាជ្ញាធរអ៊ីស្រាអែលថា ខ្លួនធ្វើទារុណកម្មជនសង្ស័យជាភេរវករ ផ្អែកតាមទ្រឹស្តីចាំបាច់នាំឲ្យ

---

[56] *សូមមើល* General Comment 31, *supra* note 50, para. 4.

[57] *សូមមើល* The European Convention of Human Rights, *supra* note 17, Art. 15(2); the ICCPR, *supra* note 30, Art. 4.

[58] *សូមមើល* Study on States of Emergency, International Commission of Jurists (ICJ), 30 the Review of the ICJ (1983), p. 1.

[59] *សូមមើល* Mark W. Janis, European Human Rights Law, text and materials, 1995, p. 121.

[60] *សូមមើល* J.Herman Burgers & Hans Danelius, *supra* note 1,_p. 120; Gail H. Miller, *supra* note 10, p. 3; Nigel S. Rodley, the Treatment of Prisoners under International Law, 2 Ed., 2002, p.44; Laurence Burgorgue –Larsen and Amaya Ubeda De Torres, the Inter-American Court of Human Rights, Case Law and Commentary, 2011, p. 362; Erika de Wet, the Prohibition of Torture as an International Norm of *Jus Cogens* and Its Implications for National and Customary Law, 15 European Journal of International Law, 2004; Chris Ingelse, the UN Committee against Torture, *supra* note 7, p. 49; England Court of Appeal, *Al-Adsani v. Government of Kuwait*, 12 March 1996.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

មានចម្លើយសារភាពទម្លាយនូវការបង្កើគ្រាប់បែក ដែលអាចសម្លាប់ជីវិតមនុស្សជាច្រើននាក់ ត្រូវបានបដិសេធចោលយ៉ាងច្បាស់ដោយតុលាការកំពូលរបស់អ៊ីស្រាអ៊ែល។[61] ចរិតដាច់ខាតនៃការហាមឃាត់អំពើទារុណកម្មនាំឲ្យកាតព្វកិច្ចមិនបញ្ជូនជនណាមួយ ទៅជួបគ្រោះថ្នាក់នៃអំពើទារុណកម្ម ក៏មានចរិតដាច់ខាតផងដែរ។[62] នេះមានន័យថា ទោះបីវត្តមានរបស់ជនណាមួយក្នុងប្រទេសបង្កឲ្យប៉ះពាល់ដល់សន្តិសុខ រដ្ឋពាក់ព័ន្ធនៅតែមិនត្រូវបញ្ជូនចេញ ប្រសិនបើទៅជួបគ្រោះថ្នាក់នៃអំពើទារុណកម្ម ដោយសារមូលហេតុបង្កអសន្តិសុខនៅក្នុងប្រទេសរបស់ខ្លួនទេ។ រដ្ឋអាចកាត់ទោសជននោះ ក្នុងស្រុករបស់ខ្លួន ឬបញ្ជូនទៅប្រទេសផ្សេង ដែលជននោះមិនជួបគ្រោះថ្នាក់ដោយសារអំពើទារុណកម្ម តែជននោះមិនអាចរួចផុតពីសំណាញ់ច្បាប់។

ទាញចេញពីចរិតនៃការហាមឃាត់ប្រភេទនេះ បញ្ហាអភ័យឯកសិទ្ធិ ការលើកលែងទោស[63] អាជ្ញាយុកាលនៃការចោទប្រកាន់[64] មិនត្រូវបានទទួលយកទេក្នុងករណីចោទប្រកាន់អំពើបទទារុណកម្ម។ ក្នុងរឿងក្តីលោក Pinochet តុលាការកំពូល (House of Lords) បានអះអាងថា ប្រទេស ឈីលី ក្រោមការដឹកនាំរបស់ លោក *Pinochet* បានចូលជាភាគីអនុសញ្ញាប្រឆាំងអំពើទារុណកម្ម ដែលធ្វើឡើងដោយអាជ្ញាធររដ្ឋ។ នេះមានន័យថា ប្រទេសឈីលី បដិសេធអភ័យឯកសិទ្ធិចំពោះអាជ្ញាធរខ្លួនដោយប្រយោល ក្នុងករណីអំពើទារុណកម្ម (Implied Waiver of Immunity) ដូចនេះ លោក *Pinochet* មិនអាចអះអាងថា គាត់មានអភ័យឯកសិទ្ធិចំពោះអំពើទារុណកម្មដែលគាត់ចូលរួមប្រព្រឹត្តឡើយ។[65]

ការបញ្ជារបស់ថ្នាក់លើឲ្យធ្វើទារុណកម្ម នឹងមិនជាការសំអាងរួចផុតពីការទទួលខុសត្រូវឡើយ។[66] វាអាចជាកត្តាបន្ថយទោស។ ទាំងអ្នកបញ្ជា និងទទួលបញ្ជា អ្នកចូលរួម ដូចជាវេជ្ជបណ្ឌិត ដែលចេញលិខិតបញ្ជាក់ក្លែងថា ជនរងគ្រោះមិនមែនស្លាប់ដោយសារទារុណកម្ម តែដោយសារការសម្លាប់ខ្លួន ត្រូវតែទទួលខុសត្រូវចំពោះអំពើទារុណកម្ម។[67] ភស្តុតាងទទួលបានពីអំពើទារុណកម្ម នឹងមិនទទួលយកជាភស្តុតាង

---

[61] *សូមមើល* *Public Committee against Torture in Israel v. Israel*, 38 L.L.M. 147, HCJ 5100/94 (1999), paras. 133-34; Ardi Imseis, 'Moderate' Torture on Trial: Critical Reflections on the Israel Supreme Court Judgment Concerning the Legality of the Central Security Service Interrogation Methods, 5(3) the International Journal of Human Rights, 2001.

[62] *សូមមើល* Lene Wendland, the Handbook on State Obligations, *supra* note 26, p. 33.

[63] *សូមមើល* Trial Chamber of the ECCC, Decision on IENG Sary's Rule 89 Preliminary Objections (*Ne bis in idem* and Amnesty and Pardon), November 2011, E51/15, para. 53.

*សូមមើល* [64] For relevance, see Trial Chamber of ECCC, Decision on the Defence Preliminary Objection concerning the Statute of Limitations of Domestic Crimes, July 2010, E187.

[65] *សូមមើល* CAT/C/SR.354, para.39; United Kingdom House of Lords: Regina Bartle and the Commissioners of Police for the Metropolis and Other Ex Parte Pinochet, 38 I.L.M. 581, 589 (March 24, 1999) (opinion of Lord Browne-Wilkinson.

[66] *សូមមើល* Antonio Cassese, International Criminal Law, 2003, pp. 231-232.

[67] *សូមមើល* United Nations, Principles of Medical Ethics relevant to the Role of Health Personnel, particularly Physicians, in the Protection of Prisoners and Detainees against Torture and Other Cruel, Inhuman or Degrading Treatment or Punishment (1982), GA Resolution 37/194; it happened in Chile that medical personnel used technique, such as prolonged beatings, to punish political dissenters, see Special Report by the Medical Profession and the Prevention of Torture, Vol 313 (7) the New England Journal of Medicine, 1102 (1985); Maxwell Gregg Bloche, Special

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

សម្រាប់ចោទប្រកាន់ជនរងគ្រោះនៃអំពើទារុណកម្ម តែអាចជាភស្តុតាងចោទប្រកាន់អ្នកប្រព្រឹត្តអំពើទារុណកម្ម។[68] ជាចុងក្រោយ មិនមានអាជ្ញាយុកាលនៃការចោទប្រកាន់ទេ សម្រាប់អំពើទារុណកម្ម។[69]

### ២.៥. អំពើទារុណកម្មក្រោមច្បាប់កម្ពុជា

ច្បាប់ចែងអំពីទារុណកម្ម មានជាយូរយារមកហើយ យ៉ាងហោចណាស់ចាប់ពីឆ្នាំ ១៩៥៦។ ច្បាប់ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បាននិយាយដោយប្រយោលអំពើទារុណកម្ម។ មាត្រាបានចែងអំពី ការគោរពនូវកិត្តិយស និងសេចក្តីថ្លៃថ្នូរ[70] និងហាមមិនទទួលយកចម្លើយសារភាពតាមរយៈការគំរាមគំហែង។[71] ក្រមសីលធម៌សម្រាប់ឆ្មាំពន្ធនាគារ បានហាមមិនឲ្យមានការធ្វើទារុណកម្ម[72] ដូចគ្នាជាមួយនឹងច្បាប់ស្តីពីពន្ធនាគារ។[73] ក្រមព្រហ្មទណ្ឌបានដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តទារុណកម្ម[74] ព្រមទាំងចាត់អំពើទារុណកម្មជាស្ថានដាក់ទម្ងន់ទោស។[75] ច្បាប់ស្តីពីការប្រឆាំងនឹងអំពើហិង្សាគ្រួសារ ក៏បាននិយាយដល់ទារុណកម្មថាជាអំពើហិង្សា។[76] ក្រមនីតិវិធីព្រហ្មទណ្ឌបាន ចែងនូវបទប្បញ្ញត្តិមួយចំនួន ស្តីពីការគ្រប់គ្រងពន្ធនាគារ។[77] បន្ថែមពីលើនេះ ក្រមព្រហ្មទណ្ឌ ចែងនូវទោសចំពោះការឃុំខ្លួនមនុស្សខុសច្បាប់[78] ការមិនដោះលែងអ្នកទោស[79]។

ក្រៅពីក្របខណ្ឌច្បាប់ក្នុងស្រុក កម្ពុជាបានចូលរួមចូលភាគី អនុសញ្ញាប្រឆាំងទារុណកម្មនិង ពិធីសារបន្ថែមលើអនុសញ្ញានេះ។[80]

---

Communications, Uruguay's Military Physicians, Cogs in a System of State Terror, JAMA, May 23/30, 18986-Vol 255, No. 20, p.1.

[68] *សូមមើល* The Torture Convention, supra note 16, Art. 15.

[69] *សូមមើល* Concluding Observation of the Committee against Torture on Sweden report, CAT/C/SWE/CO/5, 2008, para.10.

[70] *សូមមើល* 1993 Constitution in THE CAMBODIAN OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS, A SELECTION OF LAW CURRENTLY IN FORCE IN THE KINGDOM OF CAMBODIA, 5 (2005), Art. 38, *available* at http://cambodia.ohchr.org/KLC_pages/klc_english.htm

[71] *សូមមើល* *Id.*

[72] *សូមមើល* Ethics and Code of Conduct for Prison Guards (2005), item 8, in the Laws in Force in the Kingdom of Cambodia, the Cambodian Office of the High Commissioner for Human Rights, 2009.

[73] *សូមមើល* Law on the Prison, Royal Act, Year 11, Issue 96, Week 4, Dec 31 2011, p. 9239, Articles 25 and 53.

[74] *សូមមើល* 2009 Criminal Code of Cambodia (CCC), Art. 210; *id.*, law on the Prison, Article 81.

[75] *សូមមើល* *Id.*, CCC, for example, Art. 205.

[76] *សូមមើល* 2005 Law on the Prevention of Domestic Violence and the Protection of Victim, Art. 3 in the Laws in Force in the Kingdom of Cambodia, the Cambodian Office of the High Commissioner for Human Rights, 2009.

[77] *សូមមើល* 2007 Code of Criminal Procedure of Cambodia (CCP), Arts. 504-505.

[78] *សូមមើល* CCC, *supra* note 74, Art. 253.

[79] *សូមមើល* *Id.*, Art. 613.

[80] *សូមមើល* See the Laws in Force in the Kingdom of Cambodia, the Cambodian Office of the High Commissioner for Human Rights, 2009, p. 103.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាក្រាជ្ញ

### ២.៦. យន្តការទប់ស្កាត់ និង បង្ការអំពើទារុណកម្ម

ក្រោយពីចូលជាភាគីពិធីសារ កម្ពុជាបានបង្កើតជាគណៈកម្មាធិការជាតិបង្ការអំពើទារុណកម្ម។[81] គណៈកម្មាធិការនេះ ត្រូវបាននិយាយយោងក្នុងច្បាប់ស្តីពីពន្ធនាគារ។[82] គណៈកម្មាធិការ មានអំណាចពិនិត្យមើលលក្ខខណ្ឌពន្ធនាគារ សម្ភាសន៍អ្នកជាប់ឃុំដោយសម្ងាត់ ដើម្បីដាក់ចេញជាអនុសាសន៍ ដែលនឹងជួយជំរុញឲ្យស្ថានភាពពន្ធនាគារបានកាន់តែប្រសើរ។[83] ច្បាប់ស្តីពីពន្ធនាគារ ចែងក្នុងមាត្រាជាច្រើន ដែលអាចជួយបង្ការ ឬបង្ក្រាបអំពើទារុណកម្ម។ ជាក់ស្តែង អ្នកជាប់ឃុំឃាំងមានសិទ្ធិធ្វើពាក្យបណ្តឹងពីទារុណកម្មធ្វើឡើងដោយអាជ្ញាធរពន្ធនាគារ និងអ្នកជាប់ឃុំដូចគ្នា។ បណ្តឹងត្រូវតែបានឆ្លើយតបភ្លាមដោយ អាជ្ញាធរមានសមត្ថកិច្ច។[84]

### ២.៧.. បញ្ហាមួយចំនួន

### ២.៧.១. និយមន័យទារុណកម្ម

ទោះបីជា មានមាត្រាជាច្រើនបាននិយាយអំពីទារុណកម្ម ក៏ប៉ុន្តែ ច្បាប់មិនបានផ្តល់ន័យទារុណកម្មលម្អិតទេ។ ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ នៅជាធរមាន បាននិយាយថា ទារុណកម្មគឺជាអំពើបង្កឲ្យមានការឈឺចាប់។[85] ការពិនិត្យមើលមាត្រាពាក់ព័ន្ធ ធៀបនឹងនិយមន័យទារុណកម្ម តាមមាត្រា ១ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្ម រកឃើញថាមានភាពស្រពិចស្រពិលជាច្រើន។ ជាក់ស្តែង តើច្បាប់កម្ពុជា ចែងហាមឃាត់ និងដាក់ទោសទារុណកម្ម ឬទទួលស្គាល់ទារុណកម្មផ្លូវចិត្តឬទេ?។ គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម បានចោទសួរអំពី និយមន័យទារុណកម្ម។[86]

កម្ពុជា ជាចំបង អនុវត្តតាមប្រព័ន្ធ Civil Law។ នេះតម្រូវឲ្យមានច្បាប់ចែងលំអិត ទោះបីមិនទាមទារឲ្យលម្អិតគ្រប់ជ្រុងជ្រោយក្តី ប្រសិនចង់មានការធ្វើការចោទប្រកាន់ពីបទទារុណកម្ម ដោយចៅក្រម ឬព្រះរាជអាជ្ញា។ វិសោធនកម្ម ច្បាប់ផ្តល់ន័យ អ្វីជាទារុណកម្ម ជាជម្រើសមួយ ក៏ប៉ុន្តែត្រូវការពេលវេលា ដោយយោង ដល់មាត្រា ៣១ របស់ច្បាប់ធម្មនុញ្ញច្បាប់ ១៩៩៣ និងពិចារណាដល់ ប្រព័ន្ធ Civil Law ដែលតាម

[81] *សូមមើល* Sub-decree No. 122 on the Establishment of the National Preventive Mechanism against Torture and Other Cruel, Inhuman or Degrading Treatment or punishment.

[82] *សូមមើល* Law on Prison, *supra* note 73, Article 54.

[83] *សូមមើល* *Id.*

[84] *សូមមើល* Law on the Prison, *supra* note 73, Article 28.

[85] *សូមមើល* In file with the author of this article.

[86] *សូមមើល* Committee against Torture, Consideration of reports submitted by States parties under article 19 of Cambodia, CAT/C/KHM/2, para. 1.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

ទ្រឹស្តី អនុញ្ញាតឲ្យមានការប្រើប្រាស់ ឬពិចារណា មាត្រា ១ នៃអនុសញ្ញា ប្រឆាំងទារុណកម្ម ចៅក្រមអាចប្រើប្រាស់និយមន័យនៃមាត្រា ១ ហើយដាក់ទោសលើអ្នកប្រព្រឹត្ត ផ្អែកតាមក្រមព្រហ្មទណ្ឌ។[87]

## ២.៧.២. ចម្លើយសារភាព

មាត្រាពាក់ព័ន្ធ នៃការទទួលយកចម្លើយសារភាពមានភាពទូលំទូលាយ។ ទោះបីជាយ៉ាងនេះក្តី ចម្លើយសារភាពទទួលបានតាមរយៈទារុណកម្ម នឹងមិនមានតម្លៃជាភស្តុតាងទេ។[88] ការជំទាស់នឹងចម្លើយសារភាពបានកើតមាននៅមុខសាលាក្តីខ្មែរក្រហម។[89]

វិធានភស្តុតាងក្នុងតុលាការជាតិ អនុញ្ញាតឲ្យទទួលយកភស្តុតាងគ្រប់ប្រភេទ ដែលអាចរួមមានចម្លើយសារភាពផងដែរ។[90] នេះដោយសារគ្រប់សក្ខីកម្មទាំងអស់នឹងត្រូវបានដាក់មុខតុលាការដោយភាគី ហើយចៅក្រមនឹងសម្រេចអ្វីជាភស្តុតាង ដែលផ្អែកសម្រាប់វិនិច្ឆ័យសេចក្តី។[91] ទស្សនៈ «ចម្លើយសារភាពនឹងទទួលយកជាភស្តុតាងរហូតដល់គ្មានភស្តុតាងផ្ទុយ» អាចនៅតែត្រូវបានប្រកាន់យកនៅឡើយ។ ការទទួលយកចម្លើយសារភាពមកប្រើ ហាក់មានការទទួលយក និងយោគយល់ដោយមន្ត្រីតុលាការ ដោយពិចារណាលើសមត្ថភាព និងខ្វះខាតបច្ចេកទេសក្នុងការប្រមូលភស្តុតាង។

ចម្លើយសារភាពត្រូវបានគេចាត់ថាជាស្តេចនៃភស្តុតាងក្នុងសតវត្សរ៍ទី១៩។ នេះដោយសារគេពិចារណាថា វាកម្រមានជនល្មើសណាហ៊ានសារភាព ដូចនេះចម្លើយនេះ ត្រូវចាត់ថាជាភស្តុតាងចំបង។ ទោះបីជាយ៉ាងនេះក្តី ជំហរនេះលែងមានឥទ្ធិពល ដោយសារការវិវត្តទ្រឹស្តីសិទ្ធិមនុស្សដែលបង្ខំឲ្យមិនយកចម្លើយសារភាព តាមរយៈអំពើទារុណកម្ម លើកលែងតែយកមកប្រើប្រឆាំងនឹងអ្នកដែលធ្វើទារុណកម្ម។[92]

កម្ពុជាបានប្រឈមជាមួយនឹងរបបវាលពិឃាត ហើយទារុណកម្មផ្លូវកាយ ផ្លូវចិត្ត ត្រូវបានគេរាយការណ៍ ថាបានប្រព្រឹត្តិជាខ្សែសង្វាក់ពេញផ្ទៃប្រទេស។[93] នេះជាហេតុផលមួយ ក្នុងចំណោមហេតុផលមួយចំនួន ដែលនាំឲ្យមានបទប្បញ្ញត្តិ ស្តីពីទារុណកម្ម ក្នុងច្បាប់ជាច្រើន និងជម្រុញឲ្យកម្ពុជា ចូលជាភាគីអនុសញ្ញាប្រឆាំងអំពើទារុណកម្ម។ អនុសញ្ញាមិនបាននិយាយបង្គាប់ឲ្យរដ្ឋ ប្រកាន់យកវិធានការអ្វីជាក់

[87] *សូមមើល* Emmanuel Decaux, France, in Dinah Shelton, International Law and Domestic Legal Systems, 1st ed, 2011, pp. 228-229.

[88] *សូមមើល* CCP, *supra* note 77, Art. 321.

[89] *សូមមើល* IENG Sary's Motion against the Use of Torture Tainted Evidence at Trial, 4 February 2011, E33.

[90] *សូមមើល* CCP, *supra* note 77, Art. 321.

[91] *សូមមើល* Internal Rules 87 (5), the Chamber shall give the same consideration to confession as to other forms of evidence; code of criminal procedure, a confession shall be considered by the court in the same manner as other evidence. Declaration given under the physical or mental duress shall have no evidentiary value, article 321.

[92] *សូមមើល* Torture Convention, supra note 16, Art. 15.

[93] *សូមមើល* Trial Chamber, ECCC, the judgment of Case 001, 26 July 2010, para. 597.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

លាក់ក្នុងការអនុវត្តតាមអនុសញ្ញា ដោយទុកលទ្ធភាពរដ្ឋភាគី ជ្រើសរើសវិធីអនុវត្តដោយខ្លួនឯង[94] ក្នុងនាមជារដ្ឋអធិបតេយ្យភាព។ រដ្ឋត្រូវបានទាមទារឲ្យធ្វើច្បាប់ ចែងកំណត់ន័យរបស់ពាក្យ "ទារុណកម្ម" ទោះបីជាយ៉ាងនេះក្ដី រដ្ឋមិនចាំបាច់ធ្វើក៏បាន។ ក៏ប៉ុន្តែ នាពេលទារុណកម្មកើតមានឡើង រដ្ឋ តាមរយៈតុលាការ ត្រូវបកស្រាយ ឬអនុវត្តតាមន័យនៃមាត្រា ១ របស់អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ឲ្យបានពេញលេញ ដើម្បីឲ្យធានាបានយុត្តិធម៌ដល់ជនរងគ្រោះ និងមិនឲ្យជនប្រព្រឹត្តរួចផុតពីសំណាញ់ច្បាប់។ ក្នុងនាមជារដ្ឋភាគី កម្ពុជាមានកាតព្វកិច្ច គោរពតាមកាតព្វកិច្ចចែងក្នុងសន្ធិសញ្ញាដោយសុទ្ធចិត្ត។[95] តុលាការជាស្ថាប័នមួយរបស់កម្ពុជា ដែលមានកាតព្វកិច្ចធានាឲ្យមានការគោរពអនុសញ្ញា[96] ប្រសិនបើតុលាការខកខាន ឧទាហរណ៍ តាមរយៈការមិនបានពិចារណាការចោទប្រកាន់អំពីទារុណកម្ម នាំឲ្យខុសកាតព្វកិច្ចអន្តរជាតិ ដែលកម្ពុជាត្រូវទទួលខុសត្រូវចំពោះការមិនបំពេញតាមកាតព្វកិច្ចដោយតុលាការ។[97]

ចៅក្រម ត្រូវចាត់វិធានការភ្លាមតាមពាក្យបណ្ដឹង ឬតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ប្រសិនបើជនសង្ស័យ ឬ ជនត្រូវចោទ មានសញ្ញាណ ថាបានទទួលអំពើទារុណកម្ម។ ជាពិសេស ចម្លើយសារភាពគួរត្រូវបានពិចារណាឲ្យបានហ្មត់ចត់ ថាតើបានមកដោយសារអំពើទារុណកម្មឬទេ? តាមខ្លឹមសារនៃយុត្តិសាស្ត្រអន្តរជាតិ ដែលបង្កើតជាទ្រឹស្ដីការបំពាននីតិវិធី (Abuse of Process) តុលាការត្រូវ ដោះលែង ជនត្រូវចោទប្រសិន បើរកឃើញថាគាត់ត្រូវបានធ្វើទារុណកម្ម។[98] ទង្វើនេះ នឹងនាំឲ្យមិនមានការយកចម្លើយសារភាពដោយប្រើប្រាស់ទារុណកម្ម។

## ២.៨. សន្និដ្ឋាន

អំពើទារុណកម្ម ជាអំពើបង្កការឈឺចាប់ធ្ងន់ធ្ងរ ដែលជនរងគ្រោះមិនអាចត្រឡប់មករកសភាពវិញដើមបាន។ ទាំងច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិ ហាមឃាត់អំពើទារុណកម្មជាដាច់ខាត។ វិធានអន្តរជាតិបានដាក់ចេញជាកាតព្វកិច្ចជាច្រើន ដែលស្មុគស្មាញ ចំណាយថវិកា និងពេលវេលា ដល់រដ្ឋជាភាគីក្នុងករណីដែលអំពើទារុណកម្មបានកើតឡើងរួចទៅហើយ។ អាស្រ័យហេតុនេះ យន្តការពាក់ព័ន្ធត្រូវផ្ដោតលើការបង្ការជាជាងការព្យាបាល។

---

[94] *សូមមើល* Human Rights Committee, General Comment 3, Article 2 Implementation at the national level (Thirteenth session, 1981), Compilation of General Comments and General Recommendations Adopted by Human Rights Treaty Bodies, U.N. Doc. HRI/GEN/1/Rev.1 at 4 (1994), para.2.

[95] *សូមមើល* Vienna Convention on the Law of Treaties, Arts. 26 and 7; Declaration on Principles of International Law concerning Friendly Relations and Co-operation among States in accordance with the Charter of the United Nations, Friendly Declarations, in Ian Brownlie 5th ed., Basic Documents in International Law, 2002, pp. 27, 270.

[96] *សូមមើល* General Comment 31, *supra* note 50, para. 4.

[97] *សូមមើល* *Id.*

[98] *សូមមើល* Order of Provisional Detention, *supra* note 51, para. 21.

©រក្សាសិទ្ធិគ្រប់យ៉ាងដោយសាលាត្រាជូ

កម្ពុជា មានច្បាប់ និងយន្តការពាក់ព័ន្ធជាមួយនឹងការបង្ក្រាប និងបង្កាទារុណកម្មសមល្មមហើយ។ បញ្ហា គឺការអនុវត្តន៍ និងឆន្ទៈនាំឲ្យមានការអនុវត្ត។ ចៅក្រមមានតួនាទី ជាចំបងក្នុងការដាក់ទោសអ្នកធ្វើអំពើទារុណកម្ម ឬបដិសេធចម្លើយសារភាព ដែលនឹងជួយឲ្យមានការកាត់បន្ថយទារុណកម្ម។ ប្រព័ន្ធច្បាប់ជាតិ អនុញ្ញាតឲ្យចៅក្រម ប្រើច្បាប់អន្តរជាតិ ដើម្បីជួយបង្កាអំពើទារុណកម្ម។ ការខកខានរបស់តុលាការនឹងនាំកម្ពុជា រំលោភច្បាប់អន្តរជាតិ ដែលទាមទារឲ្យមានការទទួលខុសត្រូវរបស់កម្ពុជា៕